មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លេខ: 002.67/14/..../ម.ស.ម.ក/

ថ្ងៃ ទទួលបានសារនៃ
អគ្គនាយកដ្ឋាន
ចុះ
ម៉ោង 30.01.14 10:00

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤

<u>សូមគោរពជូន</u>

ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

<u>កម្មវត្ថុ</u>៖ ការបដិសេធរបស់អគ្គនាយកដ្ឋានពន្ធនាគារទៅលើសំណើសុំសួរសុខទុក្ខលោក វ៉ន ពៅ និងមនុស្ស ០៧ នាក់ផ្សេងទៀត ដែលត្រូវបានឃុំខ្លួន៣ក់ព័ន្ធនឹងបាតុកម្មកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង សហភាពការងារកម្ពុជា។

<u>យោង</u>៖ - លិខិតស្នើសុំលេខ: ០០១៩៦/ម.ស.ម.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។

- លិខិតមិនអនុញ្ញាតលេខ: ០៤៧ ស.ជ.ណ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។
- លិខិតស្នើសុំលេខ: ០០៨ /១៤/ស.ក.ក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ របស់សហភាពការងារកម្ពុជា។
- លិខិតមិនអនុញ្ញាតលេខ: ០៤៦ ស.ជ.ណ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំជាអង្គការសង្គមស៊ីវិល និងសហជីពសូមសម្តែងនូវការសោកស្តាយជាខ្លាំងជុំវិញការបដិសេធរបស់អគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃកាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ ចំពោះសំណើរបស់យើងខ្ញុំក្នុងគោលបំណងទៅសួរសុខទុក្ខលោក វ៉ន ពៅ និងសកម្មជនសិទ្ធិមនុស្សចំនួន ០៧ នាក់ផ្សេងទៀត ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២ ខែ មករា ឆ្នាំ២០១៤ នៅក្នុងការទាមទារតំឡើងប្រាក់ឈ្នួលអប្បបរមានៅមុខរោងចក្រយ៉ាក់ ជីង ហើយត្រូវបានបង្ក្រាបពីសំណាក់ទាហានឆត្រយោង៩១១ និងត្រូវបានចៅក្រមស៊ើបសួររបស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលអប់រំកែប្រែទី៣ ស្ថិតនៅឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តកំពង់ចាម។

យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា យើងខ្ញុំពុំមានគោលបំណងអាក្រក់អ្វីទេ យើងខ្ញុំមានបំណងតែមួយគត់របស់យើងខ្ញុំគឺ ដើម្បីសួរសុខទុក្ខលោក វ៉ន ពៅ និងអ្នកជាប់ឃុំចំនួន ០៧ នាក់ផ្សេងទៀតក្នុង ឋានៈជាដៃគូ និងមិត្តភក្តិដែលបម្រើការនៅក្នុងវិស័យសង្គមស៊ីវិល ដើម្បីលើកស្ទួយការគោរពសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ លើសពីនេះទៀតយើងខ្ញុំសូមជម្រាប **ឯកឧត្តម** ថា យើងខ្ញុំពុំមានអ្វីដែលត្រូវទៅរកកំង ឬ ជ្រៀតជ្រែកដល់ដំណើរការនៃការស៊ើបសួរដ៏ត្រឹមត្រូវរបស់តុលាការចំពោះសំណុំរឿងនេះទេ។ ម្យ៉ាងវិញទៀត យើងខ្ញុំក៏ពុំត្រូវបានហាមឃាត់ដោយចៅក្រមស៊ើបសួរក្នុងការមិនអនុញ្ញាតឲ្យជួបលោក វ៉ន ពៅ ដែរ។ ហេតុដូច្នេះ អគ្គនាយកដ្ឋានពន្ធនាគារ គួរ

អាសយដ្ឋាន ផ្ទះលេខ ៣៩៨ ផ្លូវលេខ ៩៩, សង្កាត់បឹងត្របែក ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ១៤០៦, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: ០២៣ ៧២៦ ៩០១ ទូរសារ: ០២៣ ៧២៦ ៩០២ អ៊ីមែល: info@cchrcambodia.org គេហទំព័រ: www.cchrcambodia.org

តែអនុញ្ញាតឲ្យយើងខ្ញុំ និងមិត្តភក្តិដទៃទៀតរបស់លោក វ៉ន ពៅ និងអ្នកជាប់ឃុំទាំងអស់ អាចជួបប្រាស្រ័យទាក់ទង និងសួរសុខទុក្ខអ្នកទាំងនោះក្នុងរយៈពេលកំណត់សមរម្យណាមួយ។

យើងខ្ញុំសូមជម្រាប **ឯកឧត្តម** ថា ល្តិកណាតែមានការហាមឃាត់ចំពោះបុគ្គលណាមួយយ៉ាងច្បាស់លាស់ពីសំណាក់ចៅក្រមស៊ើបសួរ ដើម្បីធានាប្រក្រតីភាព និងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរទើបមានការហាមឃាត់បាន ព្រោះថានៅក្នុងដំណាក់កាលនេះ មានតែចៅក្រមស៊ើបសួរនៃរឿងក្តីនេះទេ ដែលមានសិទ្ធិអំណាចក្នុងការហាមមិនឲ្យជួបចំពោះបុគ្គលជាក់លាក់មួយចំនួន ហើយដែលត្រូវកំណត់យ៉ាងច្បាស់ក្នុងដីការបស់ខ្លួន។

ការច្រានចោលពាក្យស្នើសុំរបស់យើងខ្ញុំនេះ គឺគ្មានមូលដ្ឋានច្បាប់ទាល់តែសោះ ដែលជាហេតុ ពុំអាចទទួលយកបាននោះទេ។

អាស្រ័យដូចនេះ យើងខ្ញុំសូមស្នើដល់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការ មេត្តាពិចារណាលើកលែងសំណើសុំជួបសួរសុខទុក្ខអ្នកជាប់ឃុំទាំងឡាយដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ប្រធានសហភាពការងារកម្ពុជា	អ្នកសម្របសម្រួលគម្រោងគាំទ្រអ្នកការពារសិទ្ធិមនុស្ស នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
លោក **អាត់ ចន់**	កញ្ញា **ឆាយ ឈុនលី**